# ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

# តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ

# នៅកម្ពុជា

**បទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល**

**១៧-មករា ២០១៣**

ដោយ **លេង វី** អគ្គនាយករដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ



## មាតិកា

១. ស្ថានភាពទូទៅនៃព្រះរាជាណាចក្រកម្ពុជា

២. ប្រវត្តិសង្ខេបនៃការគ្រប់គ្រងរដ្ឋបាល

៣. ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៤. គោលនយោបាយ និងក្របខណ្ឌច្បាប់

៥. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

៦. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៧. សមិទ្ធិផល

៨. បញ្ហាប្រឈមនិងដំណោះស្រាយ

# I. ស្ថានភាពទូទៅព្រះរាជាណាចក្រកម្ពុជា






| | |
|---|---|
| ផ្ទៃក្រឡា | 181,035 Km² |
| ប្រជាពលរដ្ឋ | 13,4 M |
| រាជធានី | **ភ្នំពេញ** |
| រូបិយវត្ថុ | **រៀល** (៛)<br>4,000៛=1USD |



# I. ស្ថានភាពទូទៅព្រះរាជាណាចក្រកម្ពុជា

## I.1 រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជាមុនឆ្នាំ២០០៨




**មាន៤ថ្នាក់:**

- រដ្ឋាភិបាល
- ២០ ខេត្ត និង ៤ ក្រុង
- ១៧១ ស្រុក និង ១៤ ខណ្ឌ
- ១៥១០ ឃុំ និង ១១១សង្កាត់

## I. ស្ថានភាពទូទៅព្រះរាជាណាចក្រកម្ពុជា

### I.2 រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលក្រោយឆ្នាំ២០០៨




- ក្រសួង ស្ថាប័ន
- រាជធានី និង ខេត្ត=23
- ស្រុក=159 ខណ្ឌ=9 ក្រុង=26
- ឃុំ=1407 សង្កាត់= 226

## II. ប្រវត្តិសង្ខេបនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ១. របៀបគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ដំណាក់កាលមុនឆ្នាំ១៩៧៥ :

- **<u>ថ្នាក់ឃុំ សង្កាត់</u> :** ក្រោយឆ្នាំ១៩០៨ ព្រះរាជប្រកាស ចុះថ្ងៃទី ០៥ ខែមិថុនា ត្រូវបានចាត់ទុកជាច្បាប់ ដំបូង សម្រាប់ការបង្កើត និងការគ្រប់គ្រងឃុំ នៅកម្ពុជា ជាបន្តបន្ទាប់ច្បាប់ត្រូវបានធ្វើការកែសម្រួល ដោយមានពេលខ្លះបានរៀបចំឱ្យមានការបោះឆ្នោតតែពេលខ្លះការបោះឆ្នោតត្រូវបានលុបទៅវិញ។
- **<u>ការគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ</u>** : ដោយការតែងតាំង និងបានអូសបន្លាយអស់រយៈពេលជាច្រើនទសវត្សន៍។

## II. ប្រវត្តិសង្ខេបនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ(ត)

**ដំណាក់កាលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣**

មានការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឡើងវិញ បន្ទាប់ពីមានការបំបាត់ចោល ទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់ ត្រូវបានរៀបចំឱ្យមានអាជ្ញាធរ និងបានប្រគល់នូវសិទ្ធិ អំណាច សមស្រប ព្រមជាមួយនឹងធនធានផងដែរ។

7

## II. ប្រវត្តិសង្ខេបនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ(ត)

**ដំណាក់កាលពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០២**

ក្រោយឆ្នាំ១៩៩៣ ក្នុងគោលបំណងដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សរចនាសម្ព័ន្ធ និង ប្រព័ន្ធ នៃការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បានធ្វើការកែសម្រួល ឡើងវិញ ដោយមានសមាសភាពចំរុះនៃគណបក្សនយោបាយប៉ុន្តែត្រូវបានដកហូតនូវសិទ្ធិ អំណាច និង ធនធានដែលធ្លាប់មាន។

8

## III. ឧបសគ្គនានានៃកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ

**១. មូលហេតុនៃការអនុវត្តកំណែទម្រង់ ÷**

ទី១- ប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន(ប្រជាពលរដ្ឋចូលរួមពេញលេញក្នុងការសម្រេចនិងអនុវត្តការសម្រេចនោះ)

ទី២- ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (អ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាត្រូវបានផ្ទេរ ឬបង្វិតឱ្យជិតប្រជាពលរដ្ឋ)

ទី៣- ការបង្កើនលទ្ធភាពនៃការកៀរគរប្រភពធនធានដើម្បីផ្តល់សេវា និងអភិវឌ្ឍន៍មូលដ្ឋាន ។



## III. ឧបសគ្គនានានៃ.....(ត)

**២. គោលដៅនៃការអនុវត្តកំណែទម្រង់**

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលដៅជាយុទ្ធសាស្ត្របីគឺ ៖

ទី១- ការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន

ទី២- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម

ទី៣- ការជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទង នឹងជីវភាពរស់នៅរបស់ពួកគាត់ ។

## III. ឧបសគ្គនានានៃ.....(ត)

### ៣. គោលដៅអភិវឌ្ឍន៍រយៈពេលវែង នៃការអនុវត្តកំណែទម្រង់

- កិច្ចអភិវឌ្ឍន៍ទូលំទូលាយ និងប្រកបដោយចីរភាពនៅមូលដ្ឋាន
- ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន
- គ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព
- ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព
- កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនផ្តោតលើក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ

11

## III. ឧបសគ្គនានានៃ.....(ត)

### ៤. គោលនយោបាយកំណែទម្រង់របស់រដ្ឋាភិបាល

ឆ្នាំ១៩៩៩ បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់លើវិស័យ៤ សំខាន់ គឺ :

១/ កំណែទម្រង់សេដ្ឋកិច្ច សង្គមកិច្ច

២/ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

៣/ កំណែទម្រង់រដ្ឋបាលសាធារណៈ

៤/ កំណែទម្រង់តុលាការ យុត្តិធម៌

12

## III. ទស្សនទាននៃ.....(ត)

### ៥. គោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល(ត)

**គោលបំណង :**

- មានតម្លាភាពដើម្បីពង្រឹងការគ្រប់គ្រងដោយច្បាប់
- ដើម្បីធ្វើឱ្យការផ្តល់សេវានៅថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ កាន់តែបានខិតទៅកៀកជិតនឹងប្រជាពលរដ្ឋ
- បំពេញនាទីជាកាតាលីករឱ្យការផ្តួចផ្តើមគំនិតរបស់ផ្នែកឯកជន
- មានគណនេយ្យភាព ដោយបញ្ចូលគំនិតថ្មី និង កាន់តែមានលក្ខណៈវិជ្ជាជីវៈ ដើម្បីបង្កើនផលិតភាព និងកែលំអគុណភាពសេវាដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ។



## IV. ក្របខណ្ឌគោលនយោបាយ និង ច្បាប់

១.១ - ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

១.២ - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាន អនុម័តនិង ប្រកាសឱ្យប្រើប្រាស់ នាឆ្នាំ២០០១

១.៣ - ក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនាខែមិថុនា ឆ្នាំ២០០៥

១.៤ - ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

១.៥ - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបាន អនុម័ត និង ប្រកាសឱ្យប្រើប្រាស់ នាខែឧសភា ឆ្នាំ ២០០៨។

## IV. ក្របខណ្ឌគោលនយោបាយ និង ច្បាប់(ត)

១.៦ - កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

១.៧ - ផែនការអនុវត្តកម្មវិធីជាតិរយៈពេលពាឆ្នាំដំបូង

១.៨ - លិខិតបទដ្ឋានជាច្រើនថែមទៀតសម្រាប់អនុវត្ត



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (គោលការណ៍សំខាន់ៗនៃច្បាប់)

ច្បាប់នេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាលចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដោយកំណត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីពីរ គឺតួនាទីជា ៖

**១.** បម្រើកិច្ចការមូលដ្ឋានសម្រាប់ផលប្រយោជន៍ប្រជាពលរដ្ឋខ្លួន(វិមជ្ឈការ)

២. ភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬប្រគល់អំណាច (វិសហមជ្ឈការ)

ទន្ទឹមនោះក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានការផ្ទេរមូលនិធិពីថ្នាក់ជាតិសម្រាប់ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខ្លួន។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ១. គោលបំណង

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់កំណត់ឱ្យមានការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

**គោលបំណងនៃការគ្រប់គ្រងឃុំ សង្កាត់តាមបែបវិមជ្ឈការ គឺ :**

- ❑ លើកកំពស់ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃជីវភាព
- ❑ ផ្តល់ជូនប្រជាជនធម្មតានូវឱកាសកាន់តែច្រើនដើម្បីចូលរួមធ្វើសេចក្តីសំរេចចិត្ត
- ❑ ធានានូវកិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ដោយរាប់បញ្ចូលទាំងការផ្តល់សេវាជាមូលដ្ឋានផង ។



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ២. <u>គោលដៅសំខាន់ៗ</u>

- ❑ ការផ្តល់ភាពជានីតិបុគ្គលឱ្យឃុំ សង្កាត់
- ❑ ការបង្កើតឡើងនូវប្រព័ន្ធនៃអភិបាលកិច្ចនៅថ្នាក់ឃុំ សង្កាត់
- ❑ អំណាចដឹកនាំគ្រប់គ្រងឃុំ សង្កាត់ គឺត្រូវកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងក្របខ័ណ្ឌឃុំ សង្កាត់នីមួយៗ
- ❑ ការផ្តល់នូវអំណាចបញ្ញត្តិ និង អំណាចប្រតិបត្តិឱ្យឃុំ សង្កាត់
- ❑ កំណត់អំពីការរៀបចំកែសម្រួលព្រំប្រទល់ឃុំ សង្កាត់ ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

**៣. ការផ្ទេរភាពជាម្ចាស់នៃអំណាច និងភារកិច្ចពេញលេញទៅឱ្យរដ្ឋបាលឃុំ សង្កាត់**

- ក្រុមប្រឹក្សាឃុំ សង្កាត់មានការទទួលខុសត្រូវ និង មានគណនេយ្យភាពចំពោះមុខសហគមន៍
- ធានាឱ្យសហគមន៍មូលដ្ឋានអាចចូលរួមក្នុងការតាក់តែងគោលនយោបាយ និងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ការផ្ទេរភាពជាម្ចាស់នៃអំណាច និងភារកិច្ចពេញលេញទៅឱ្យរដ្ឋបាលឃុំសង្កាត់
- ការធានាឱ្យរដ្ឋបាលឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុផ្ទាល់
- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដល់សមាជិកក្រុមប្រឹក្សា ដែលបានជាប់ឆ្នោត និងមន្ត្រីដែលបានចាត់តាំងនៅក្នុងឃុំ សង្កាត់ទាំងនេះ ។



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៤. ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោតដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ក្នុងអាណត្តិ៥ឆ្នាំ ។
- ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់នីមួយៗ ត្រូវបានកំណត់ដោយផ្អែកលើប្រជាសាស្ត្រ និងភូមិសាស្ត្រ
- ក្រុមប្រឹក្សាឃុំ សង្កាត់នឹងត្រូវរំសាយ ក្នុងករណីដែលធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានា ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៤. ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ (ត)

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**អាណត្តិទី១**

- ☞ អ្នកចូលរួមបោះឆ្នោត ជាង ៤.៥០០.០០០ នាក់
- ☞ បេក្ខជនឈរឈ្មោះ ៧៥.៦៥៥ នាក់ (៨ គណបក្សនយោបាយចូលរួម) ក្រុមប្រឹក្សាឃុំ សង្កាត់ ១.៦២១
- ☞ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១១.២៦១ នាក់ មានសមាសភាពមកពី ៤ គណបក្សនយោបាយត្រូវបានជ្រើសរើស ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៤. ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ (ត)

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**អាណត្តិទី២**

- ☞ អ្នកចូលរួមបោះឆ្នោតជិត៥.៣លាននាក់ លើចំនួនអ្នកបោះឆ្នោតរួម ៧.៧៩៩.៣៧១នាក់
- ☞ បេក្ខជនឈរឈ្មោះ១០២.២៦៦ នាក់ (គណបក្សនយោបាយចូលរួមចំនួន ១២)
- ☞ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១១.៣៥៣នាក់ មានសមាសភាពមកពី ៥ គណបក្សនយោបាយ ។
- ☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ១.៦២១ ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

**៤. ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ (ត)**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**អាណត្តិទី៣**

☞ អ្នកបានទៅបោះឆ្នោត ៥.៩៩៣.៩៩២នាក់ លើចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៩.២០៣.៤៩៣នាក់

☞ បេក្ខជនឈរឈ្មោះ ១១១.០៥៦នាក់ ក្នុងនោះស្រី ២៨.៤៨១ (គណបក្សនយោបាយចូល រួមចំនួន១០)

☞ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត១១.៤៥៩នាក់ មានសមាសភាពមកពី ៧ គណបក្សនយោបាយ ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់ ១.៦៣៣ ឃុំ សង្កាត់ ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

**៥. <u>អំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់</u>**

មានតែក្រុមប្រឹក្សាប៉ុណ្ណោះ ទើបអាចសំរេច និងអនុម័ត :

- ផែនការអភិវឌ្ឍន៍របស់ខ្លួន
- ថវិការបស់ខ្លួន
- អត្រាពន្ធ ថ្លៃឈ្នួល និងកំរៃផ្សេងៗ
- បទបញ្ជាផ្ទៃក្នុងឃុំ សង្កាត់
- កិច្ចការផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៦. ភារកិច្ច

**ភារកិច្ចផ្ទាល់(វិមជ្ឈការ)**

រក្សា និង ពង្រីក ៖
- សន្តិសុខ និង សណ្តាប់ធ្នាប់
- ការផ្តល់សេវាសាធារណៈ
- ផាសុកភាព សុខមាលភាព
- អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមលើកកំពស់ជីវភាពរស់នៅ
- ការពារបរិស្ថាន និងធនធានធម្មជាតិ
- សាមគ្គីភាព
- កិច្ចការទូទៅ

ភារកិច្ចជាភ្នាក់ងារ (វិសហមជ្ឈការ)

- **តំណាងឱ្យរដ្ឋ**
- **ប្រតិភូកម្ម និង ក្រោមអាជ្ញាធរ រដ្ឋ**
- **ទទួលការរំលែកពីរដ្ឋ**

**ភារកិច្ចដែលរដ្ឋដកហូត**

-កិច្ចការបរទេស
-ពន្ធដារ
-វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។
-ព្រៃឈើ
-ប្រៃសណីយ៍ ទូរគមនាគមន៍
-ការពារជាតិ
-សន្តិសុខជាតិ
-រូបិយវត្ថុ

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៧. រចនាសម្ព័ន្ធនិងប្រព័ន្ធ



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៨. ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

- ផែនការការអភិវឌ្ឍន៍ជាកាតព្វកិច្ច ក្រុមប្រឹក្សាត្រូវអនុម័តផែនការអភិវឌ្ឍន៍របស់ខ្លួននៅក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន ហើយត្រូវពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។
- ប្រឹក្សាទាំងអស់ ត្រូវរៀបចំ អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ ដែលកំណត់ បង្កើតកម្មវិធីសំរាប់ការអភិវឌ្ឍន៍ឃុំ សង្កាត់
- ផែនការនេះ ត្រូវស្របទៅតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ជាតិ



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៨. ផែនការអភិវឌ្ឍរបស់ឃុំ សង្កាត់(ត)

បានរៀបចំឡើងស្របតាមគោលបំណងដែលច្បាប់បានកំណត់ :

- ✓ មានការចូលរួម
- ✓ មានការឆ្លើយតប
- ✓ មានការទទួលខុសត្រូវ
- ✓ មានភាពសមស្រប និងអាចអនុវត្តបាន
- ✓ មានការអភិវឌ្ឍពិតប្រាកដ និងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៩. ហិរញ្ញវត្ថុឃុំ សង្កាត់

ឃុំ សង្កាត់ ត្រូវមានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់ ។

៩.១ <u>ធនធានហិរញ្ញវត្ថុរបស់ឃុំ សង្កាត់រួមមាន</u> :

- ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកំរៃផ្សេង"(ពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិង ពន្ធលើការជួល)
- ឃុំ សង្កាត់មានសិទ្ធិទទួលបានធនធានវិភាជន៍ពីចំណូលរដ្ឋ
- ឃុំ សង្កាត់មានសិទ្ធិទទួលបានប្រាក់កំរៃក្នុងការបំពេញមុខងារជាទីភ្នាក់ងារ តំណាងឱ្យរដ្ឋ


## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)


### ៩. ហិរញ្ញវត្ថុឃុំ សង្កាត់ (ត)

### ៩.២. គោលការណ៍នៃការរៀបចំនិងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ :

- បានដំណើរការតាមលក្ខណៈប្រជាធិបតេយ្យ មានការចូលរួម មានតម្លាភាព មានការទទួលខុសត្រូវ មានប្រសិទ្ធភាព និងមានការឆ្លើយតប
- រតនាគារខេត្ត ក្រុងបានដើរតួនាទីយ៉ាងសំខាន់ជាគណនេយ្យកររបស់ឃុំ សង្កាត់
- ក្រុមការងារគណនេយ្យភាពបង្កើតឡើងនៅតាមខេត្ត ក្រុង និងថ្នាក់ជាតិ
- មានការពិនិត្យតាមដាន និងធ្វើសវនកម្ម (សវនកម្មផ្ទៃក្នុង និងសវនកម្មពីខាងក្រៅ)

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

### ៦. ហិរញ្ញវត្ថុឃុំ សង្កាត់ (ត)

### ៩.៣. គោលការណ៍នៃការបែងចែក :

- ចំណាយរដ្ឋបាលទូទៅ មិនលើស ៣០ភាគរយ ចំណាយអភិវឌ្ឍន៍ មិនតិចជាង ៧០ភាគរយ
- ការបែងចែកឱ្យឃុំ សង្កាត់នីមួយៗ អនុវត្តតាមរូបមន្ត :
  - ការបែងចែកស្មើភាគគ្នា ៣៥ ភាគរយ
  - ការបែងចែកតាមចំនួនប្រជាពលរដ្ឋ ៣៥ ភាគរយ
  - ការបែងចែកតាមកំរិតភាពក្រីក្រ ៣០ ភាគរយ



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)

**ហិរញ្ញវត្ថុឃុំ សង្កាត់ (ត)** ថវិកាដែលបានវិភាជទៅក្នុងមូលនិធិឃុំ សង្កាត់

| ឆ្នាំ | ថវិការដ្ឋ | UNDP | សរុប | ចំនួនគំរោង |
|---|---|---|---|---|
| 2002 | 6,253,665 | 1,418,313 | 7,671,978 | |
| 2003 | 10,904,882 | 1,950,000 | 12,854,882 | |
| 2004 | 12,500,000 | 2,000,000 | 14,500,000 | |
| 2005 | 14,500,000 | 2,025,000 | 16,525,000 | |
| 2006 | 17,403,500 | 2,050,000 | 19,453,500 | |
| 2007 | 21,875,000 | 512,500 | 22,387,500 | |
| 2008 | 22,750,000 | 506,250 | 23,256,250 | |
| 2009 | 26,722,500 | 1,537,500 | 28,335,000 | |
| 2010 | 37,143,500 | 1,666,558 | 38,810,058 | |
| 2011 | 39,850,000 | | 39,850,000 | |
| 2012 | 44,930,000 | | 44,930,000 | |

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

**១០. ការពិនិត្យតាមដាន ការគាំទ្រ និង ការធ្វើអន្តរាគមន៍**

**គោលបំណងរួម :**

- ត្រួតពិនិត្យនីត្យានុកូលភាពលើការគ្រប់គ្រង ការអនុវត្តអំណាច និងការបំពេញមុខងារ និង ភារកិច្ចរបស់ឃុំ សង្កាត់ ។
- វាយតំលៃលើការវិវត្តសមត្ថភាពរបស់ឃុំ សង្កាត់ ។
- វាយតំលៃលើកំរិតដែលរដ្ឋាភិបាល គួរធ្វើអន្តរាគមន៍ ឬផ្តល់ជំនួយឧបត្ថម្ភដល់ឃុំ សង្កាត់ដើម្បី ពង្រឹងការគ្រប់គ្រង គារអនុវត្តអំណាច និងការបំពេញមុខងារភារកិច្ចរបស់ឃុំ សង្កាត់ ។



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត)
## (គោលការណ៍សំខាន់ៗនៃច្បាប់)

**១១. យន្តការគាំទ្រដល់ការអនុវត្តច្បាប់**

**១១.១- រចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្រនៅថ្នាក់ជាតិ**

ដើម្បីអនុវត្តច្បាប់ និង ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងដំណាក់កាល ដំបូង ច្បាប់បានតំរូវអោយបង្កើតគណៈកម្មាធីការអន្តរក្រសួងមួយ ឈ្មោះថា **គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ "គ.ឃ.ស"** ក្រោយមកជា **គណៈកម្មាធិការដឹកនាំកាងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ** និងបច្ចុប្បន្នជា **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ដែលជាយន្តការអន្តរវិស័យ ។

## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត) (គោលការណ៍សំខាន់ៗនៃច្បាប់)

### ១១. យន្តការគាំទ្រដល់ការអនុវត្តច្បាប់(ត)

១១.២. តួនាទីភារកិច្ចគ.ឃ.ស ធ្វើសកម្មភាពសំខាន់ៗដូចខាងក្រោម :

- សម្រួលសម្រួលដើម្បីពិភាក្សា និងដាក់ចេញនូវលិខិតបទដ្ឋាននានាដើម្បីអនុវត្តច្បាប់"
- សម្របសម្រួលក្នុងការរៀបចំបង្កើតមូលនិធិឃុំ សង្កាត់ និងការវិភាជថវិកាទៅក្នុងមូលនិធិនេះ
- ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធ
- ការសម្រះសម្រួលទំនាស់តូចតាចនៅក្នុងក្រុមប្រឹក្សា
- ការត្រួតពិនិត្យនីត្យានុកូលភាព និង ការតាមដានរាល់សកម្មភាពគាំទ្រឃុំ សង្កាត់ របស់រាជធានី ខេត្ត



## V. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(ត) (គោលការណ៍សំខាន់ៗនៃច្បាប់)

### ១១. យន្តការគាំទ្រដល់ការអនុវត្តច្បាប់(ត)

១១.៣- <u>រចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្រនៅថ្នាក់រាជធានី ខេត្ត មុនឆ្នាំ ២០១១</u>



## VI- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១. ទិដ្ឋភាពទូទៅ

ច្បាប់នេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ ៖

- កំណត់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការរៀបចំអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ការរៀបចំរដ្ឋបាលឯកភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការកំណត់អភិបាលកិច្ចនៅទីប្រជុំជន និងទីជនបទ
- ការពិនិត្យ និងផ្ទេរមុខងារ ធនធាន និងបុគ្គលិកទៅរដ្ឋបាលថ្នាក់ក្រោមជាតិ



## VI- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ២. គោលបំណង

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**២. គោលបំណង(ត)**

រដ្ឋបាលឯកភាព គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សាដែល ៖

អាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន និងមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងក្រសួង ស្ថាប័ន នានារបស់រាជរដ្ឋាភិបាល ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

39

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៣. គោលការណ៍ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន ៖

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។ (មាត្រា១២)

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៤.គោលការណ៍សំខាន់ៗ

- ការផ្តល់ឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនូវភាពជានីតិបុគ្គលនៃនីតិសាធារណៈ
- អាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន
- មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៥. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**៦-អំពីក្រុមប្រឹក្សា**

៦.១ ការបង្កើតក្រុមប្រឹក្សា

- រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលជ្រើសរើសឡើង តាមការបោះឆ្នោតអសកល (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ជាអង្គបោះឆ្នោត)
- ក្រុមប្រឹក្សាមានអាណត្តិប្រាំឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**៦-អំពីក្រុមប្រឹក្សា (ត)**

៦.២-សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាមានសិទ្ធិអំណាចខាងធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងប្រតិបត្តិ :

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ : ដោយការធ្វើដីកា
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ : ដោយធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សាត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំ  របស់ក្រុមប្រឹក្សា និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៦-អំពីក្រុមប្រឹក្សា (ត)

៦.៣-តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា

- *កសាងផែនការ :* ត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ កម្មវិធី វិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ
- *គ្រប់គ្រងហិរញ្ញវត្ថុ :* ត្រូវចាត់ចែងហិរញ្ញវត្ថុសាធារណៈដើម្បីជម្រុញការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍន៍សំខាន់បំផុត
- *តាមដានត្រួតពិនិត្យ វាយតម្លៃ :* ក្រុមប្រឹក្សាត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃ ជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍន៍ 45

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៦-អំពីក្រុមប្រឹក្សា (ត)

**៦.៣ - អំពីតួនាទី ភារកិច្ច របស់ក្រុមប្រឹក្សា (ត)**

- *គ្រប់គ្រងបុគ្គលិក :* ត្រូវត្រួតពិនិត្យ និងសម្រេចការតែងតាំង ការបណ្តេញចេញ ការកម្រឹតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងទៀត
- *រៀបចំរបាយការណ៍ :* ត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ
- *ផ្សព្វផ្សាយព័ត៌មាន :* ត្រូវបង្កលក្ខណៈងាយស្រួលឱ្យសាធារណជនទទួលព័ត៌មាន
- *ទប់ស្កាត់សកម្មភាពរំលោភអំណាច :* ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខអក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៧. អំពីគណៈអភិបាល និងអភិបាល

### ៧.១ ការតែងតាំងគណៈអភិបាល

- គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានគណៈអភិបាលដែលតែងតាំងឡើងដោយរាជរដ្ឋាភិបាល មានអាណត្តិ៤ឆ្នាំ
- *គណអភិបាល*មានប្រធាន០១រូប ហៅថា អភិបាល និង អភិបាលរងមួយចំនួន *ដែល*កំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ការតែងតាំងអភិបាល និងអភិបាលរងត្រូវធ្វើឡើងស្របតាមច្បាប់កំណត់។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៧. អំពីគណៈអភិបាល និងអភិបាល (ត)

### ៧.២- តួនាទីរបស់គណៈអភិបាល

- គណៈអភិបាលត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយជូនក្រុមប្រឹក្សានិងជាអ្នកអនុវត្ត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- គណៈអភិបាលត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានដែលបានបែងចែក ឬបានផ្ទេរ។
- គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និង ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សាដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៧. អំពីគណៈអភិបាល និងអភិបាល (ត)

### ៧.២- តួនាទីរបស់គណៈអភិបាល(ត)

- គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី :
  - ការបង្កើត ឬរំសាយអង្គភាព
  - ការងារបុគ្គលិក (ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង រៀបចំ តួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងារ ការកំណត់ប្រាក់បៀវត្ស និងប្រាក់កំរៃ ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក
  - ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិក
  - ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៧. អំពីគណៈអភិបាល និងអភិបាល (ត)

### ៧.២- តួនាទីរបស់គណៈអភិបាល(ត)

- គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សា ដើម្បីពិនិត្យ និងអនុម័តនូវ :
  - កម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំ និងគំរោងថវិកាប្រចាំឆ្នាំ
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (០៥) ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដោយត្រូវធានាឱ្យផែនការសកម្មភាព និង ថវិការបស់បណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលផ្តល់សេវា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំ រំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**៧. អំពីគណៈអភិបាល និងអភិបាល (ត)**

**៧.៣- តួនាទីរបស់អភិបាល :**

- អភិបាល មានតួនាទីជាជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាពខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសន្តិសុខសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា។



## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៨. គណៈកម្មាធិការជំនួយការ

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវបង្កើតឡើងនូវគណៈកម្មាធិការជំនួយការចំនួន ៣:

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម និងអាចរៀបចំបង្កើតគណៈកម្មាធិការផ្សេងទៀតតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជំនួយការនេះ នឹងត្រូវកំណត់ដោយអនុក្រឹត្យ និងប្រកាស។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៩. បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា

បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងត្រួតពិនិត្យផ្ទាល់ដោយគណៈអភិបាល ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិករបស់ក្រុមប្រឹក្សា រួមមាន ៖

-បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា

-បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា

-បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា

-ក្រុមប្រឹក្សានីមួយៗមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយក្រសួងមហាផ្ទៃ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១០ - គណនេយ្យភាព

ក្រុមប្រឹក្សា មានគណនេយ្យភាពចំពោះ ៖

-ប្រជាពលរដ្ឋ

-រាជរដ្ឋាភិបាល

ដោយឡែកក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់

គណៈអភិបាល មានគណនេយ្យភាពចំពោះ ៖

-រាជរដ្ឋាភិបាល

-ក្រុមប្រឹក្សា

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១១. យន្តការគាំទ្រការអនុវត្តច្បាប់

**១១.១** - ការបង្កើតគណកម្មាធិជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

គ.ជ.អ.ប មានសមាជិកមកពីក្រសួង ស្ថាប័ន ពាក់ព័ន្ធចំនួន១៣របស់រាជរដ្ឋា - ភិបាល

គ.ជ.អ.ប ត្រវមានអនុគណៈកម្មាធិការ ៖

- -អនុគណៈកម្មាធិការមុខងារ និងធនធាន
- -អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
- -អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- -អនុគណៈកម្មការផែនការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

គ.ជ.អ.ប អាចបង្កើតអនុគណៈកម្មាធិការផ្សេងៗទៀតជាជំនួយការតាមការចាំបាច់

គ.ជ.អ.ប ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការដែលស្ថិតនៅក្នុងក្រសួងមហាផ្ទៃ



## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១១.១ រចនាសម្ព័ន្ធ គ.ជ.អ.ប



## រចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប






## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១១.២. តួនាទី ភារកិច្ចរបស់ គ.ជ.អ.ប

- ពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់
- ធានាថាក្រសួង ស្ថាប័នរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ បានធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍ និងថវិការបស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា (សម្រាប់តែអំឡុងពេលនៃការរង់ចាំការផ្ទេរមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សានីមួយៗប៉ុណ្ណោះ)
- ធានាថា ច្បាប់នេះត្រូវអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១១.២. តួនាទី ភារកិច្ចរបស់ គ.ជ.អ.ប (ត)

- ធានាថា គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានា មានសង្គតិភាពជាមួយច្បាប់នេះ

- ផ្តល់អនុសាសន៍ដោយផ្ទាល់ដល់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយ អំពីការតាក់តែង ឬធ្វើវិសោធនកម្មច្បាប់ ឬលិខិតបទដ្ឋាននានាដើម្បីឱ្យស្រប ច្បាប់នេះ

- ដោះស្រាយ ឬលើកសំណើរសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល លើបញ្ហា មិនចុះសម្រុងគ្នាដែលកើតមានទាក់ទងនឹងច្បាប់នេះ



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១២ - ដំណើរការនៃការអនុវត្តច្បាប់

### ១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

### ក. ការពិនិត្យមុខងារឡើងវិញ

គ.ជ.អ.ប ពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវ របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារ និងការទទួលខុសត្រូវ ដែលនឹងត្រូវ ៖

-ផ្ទេរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង ខេត្ត រាជធានី ឬ

-រក្សាទុកជាមុខងារ និងការទទួលខុសត្រូវរបស់ថ្នាក់ជាតិ

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)**

**ក. ការពិនិត្យមុខងារឡើងវិញ (ត)**

ប្រភេទមុខងារ

-មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យឬអនុក្រឹត្យ ឬប្រកាស

-មុខងារជម្រើស គឺជាមុខងារទាំងឡាយណាដែលមិនមានលក្ខណៈជាកាតព្វកិច្ច។

61

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)**

**ក - ការពិនិត្យមុខងារឡើងវិញ (ត)**

ក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ត្រូវផ្តោតលើវិស័យជាអាទិភាព មានដូចខាងក្រោម ៖

-កសិកម្ម អប់រំ

-ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន

-សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច

ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច

62

-ការប្រើប្រាស់ដីធ្លី

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

### ក. ការពិនិត្យមុខងារឡើងវិញ (ត)

-ការផលិត និងការចែកចាយអគ្គិសនី

-ការគ្រប់គ្រងទឹក ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយសម្ភារចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែងការទទួលខុសត្រូវទាំងនេះ និងតម្រូវការពិសេសឬតម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រនិងកេរ្តិ៍តំណែលវប្បធម៌ផងដែរ ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

### ក. ការពិនិត្យមុខងារឡើងវិញ (ត)

ការពិនិត្យមើលមុខងារ សម្រាប់ផ្ទេរឱ្យប្រភេទក្រុមប្រឹក្សានីមួយៗត្រូវផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

-ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-អាចគ្រប់គ្រង និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-បម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ

-មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

## VI- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

ខ). របៀបផ្ទេរមុខងារ

ក្នុងការផ្ទេរមុខងារ គ.ជ.អ.ប ត្រូវ ៖

-កំណត់មុខងារណាមួយជាមុខងារជាកាតព្វកិច្ច ឬមុខងារជាជម្រើស
-កំណត់មុខងារណាត្រូវប្រគល់ ឬត្រូវធ្វើប្រតិភូកម្ម
-មុខងារជាកាតព្វកិច្ចធ្វើឡើងដោយការប្រគល់ ឬដោយការធ្វើប្រតិភូកម្មឱ្យប្រភេទក្រុមប្រឹក្សាដែលសមស្រប
-មុខងារជាជម្រើសត្រូវប្រគល់ឱ្យក្រុមប្រឹក្សាប្រភេទណាមួយដែលសមស្រប ។

៦៥

## VI- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ៨.៤. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

<u>ការប្រគល់មុខងារ</u> ៖ គឺជាការផ្ទេរមុខងារ ធនធានទៅឱ្យក្រុមប្រឹក្សាណាមួយដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយមិនតម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នពាក់ព័ន្ធឡើយ ។

<u>ការធ្វើប្រតិភូកម្មមុខងារ</u> ៖ គឺជាការផ្ទេរមុខងារ ធនធាន ឱ្យទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយតម្រូវឱ្យមានការចូលរួមចំណែកជាប្រចាំពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

៦៦

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១២.១. ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

ខ). របៀបផ្ទេរមុខងារ(ត)

ការកំណត់ និងការផ្ទេរមុខងារត្រូវធ្វើឡើងដោយរួមជាមួយនឹង ៖

-ការផ្ទេរធនធានរួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ

-ការផ្តល់លទ្ធភាព និងអំណាច ដើម្បីទទួលបានធនធានទាំងនោះ

-ការផ្តល់អំណាច និងភារកិច្ច ដើម្បីគ្រប់គ្រង និងអនុវត្តរាល់មុខងាររបស់ខ្លួនតាមគោលការណ៍ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពនៅមូលដ្ឋានក្នុងកម្រិតជាអតិបរមា។

67

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៣. របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក). ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

- រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ហៅកាត់ថា ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

  - ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី។

- សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង។

68

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**១៣. របបហិរញ្ញវត្ថុ... (ត)**

ខ). ប្រភពចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក មានសិទ្ធិទទួលបានចំណូល ៖

-ពីប្រភពនៅមូលដ្ឋាន

-ពីប្រភពនៅថ្នាក់ជាតិ និង

-ពីប្រភពផ្សេងៗទៀត ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**១៣. របបហិរញ្ញវត្ថុ... (ត)**

**គ. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ៖

-ទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរឱ្យ និង

-ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង។

គ.ជ.អ.ប អាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬច្រើនប្រើប្រាស់រួមគ្នានូវទ្រព្យសម្បត្តិណាមួយ ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**គ. ការគ្រប់គ្រងទ្រព្យ...(ត)**

រដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រប់គ្រងនិងប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ គ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយគ្មានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីក្រសួងមហាផ្ទៃបានឡើយ ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៤. ការកែសម្រួល និងរៀបចំបុគ្គលិកឡើងវិញ

- គ.ជ.អ.ប និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវពិនិត្យ និងកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកស្របពេល ជាមួយនឹងការផ្ទេរមុខងារ និងភារកិច្ច ក្នុងគោលបំណងបង្កើតឱ្យមានក្របខ័ណ្ឌបុគ្គលិក របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ.ជ.អ.ប ត្រូវមានការទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយយុទ្ធសាស្ត្រ សម្រាប់ធានាឱ្យការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិកឱ្យបានសមស្រប ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៤. ការកែសម្រួល...(ត)

ក្នុងការកែសម្រួលបុគ្គលិកឡើងវិញ គ.ជ.អ.ប ត្រូវធានាមិនឱ្យមានការបង្កើនចំនួនបុគ្គលិកមុខងារសាធារណៈ ។

បុគ្គលិកមុខងារសាធាណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក ។

ក្នុងករណីមុខងារ ភារកិច្ចណាមួយត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា បុគ្គលិកដែលធ្លាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ភារកិច្ចនោះ ក៏ត្រូវធ្វើការផ្ទេរទៅឱ្យក្រុមប្រឹក្សានោះដែរ ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៤. ការកែសម្រួល...(ត)

ក្នុងករណីមុខងារ ភារកិច្ចណាមួយត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា ហើយបុគ្គលិកចាំបាច់មានចំនួនមិនគ្រប់គ្រាន់ ឬគ្មានតែម្តង ក្រុមប្រឹក្សាត្រូវបានទទួលធនធានហិរញ្ញវត្ថុ ដើម្បីជ្រើសរើសបុគ្គលិកមកបម្រើការងារតាមការចាំបាច់ ។

បើបុគ្គលិកមិនយល់ព្រមតាមការកែសម្រួលរៀបចំឡើងវិញ សាមខ្លួនត្រូវបញ្ជាក់អំពីមូលហេតុ ។ បុគ្គលិកនោះអាចបន្តស្ថិតនៅជាបុគ្គលិករបស់ក្រសួង ស្ថាប័នជាបន្តទៀត ប៉ុន្តែត្រូវប្រគល់ភារកិច្ចផ្សេង ។

## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៥-តួនាទីរបស់ក្រសួងស្ថាប័ន

ចូលរួមសហការជាមួយ គ.ជ.អ.ប ក្នុងការពិនិត្យអំពីតួនាទី ភារកិច្ចរបស់ក្រសួង ស្ថាប័នសាមី ដើម្បីកំណត់ថាតើ ៖

មុខងារណាត្រូវផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមុខងារណាត្រូវរក្សាទុកនៅថ្នាក់ជាតិ ពិសេសលើវិស័យអាទិភាព ដែលបានកំណត់ដោយច្បាប់នេះ។



## VI- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១៥-តួនាទីរបស់ក្រសួងស្ថាប័ន (ត)

-ផ្ទេរធនធាន ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងបុគ្គលិកទៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របនឹងការផ្ទេរមុខងារ

-ធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សា

-ចូលរួមជាមួយ គ.ជ.អ.ប ក្នុងការពិនិត្យ និងកែសម្រួលឡើងវិញលើមុខងារដែលបានប្រគល់ ឬប្រតិភូកម្មកន្លងមក។

## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ត)

**១៦-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ :**

- ដោយកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិមានភាពស្មុគស្មាញ សាំញ៉ាំ និងរសើបតម្រូវឱ្យមានការរៀបចំកម្មវិធីជាតិមួយសម្រាប់អនុវត្ត ។
- កម្មវិធីនិងកំណត់នូវផែនការសកម្មភាពសម្រាប់រយៈពេល១០ឆ្នាំ ២០១០-២០១៩ ដែលក្នុងនោះ នឹងកំណត់ផែនការសកម្មភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- កម្មវិធីជាតិត្រូវបានរាជរដ្ឋាភិបាលអនុម័តក្នុងខែឧសភា ឆ្នាំ២០១០
- បន្ទាប់ពីមានកម្មវិធីជាតិ មានផែនការអនុវត្តកម្មវិធីជាតិ៣ឆ្នាំដំបូង និងមានផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំនីមួយៗ។



## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ត)

**១៦-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (ត):**

ខ្លឹមសារសំខាន់ៗនៃកម្មវិធីជាតិគឺការបង្កើតឡើងនូវសមាសធាតុកម្មវិធីចំនួន៥ ដូចខាងក្រោម :

**១- សមាសធាតុកម្មវិធីទី១** មានគោលបំណង ពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈ ការលំអរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយ ដោយផ្អែកតាមគោលការណ៍នៃការចូលរួម តាមបែបប្រជាធិបតេយ្យ។

**២- សមាសធាតុកម្មវិធីទី២** មានគោលបំណងគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារ មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។

## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ត)

**១៦-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (ត):**

**៣- សមាសធាតុកម្មវិធីទី៣** មានគោលបំណងសិក្សានិងផ្ទេរមុខងារពីថ្នាក់ជាតិទៅឱ្យថ្នាក់ក្រោមជាតិ ធានាការលើកកម្ពស់បរិមាណ និងគុណភាពសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និង ធនធានដែល បានផ្ទេរ ។

**៤- សមាសធាតុកម្មវិធីទី៤** មានគោលបំណងបង្កើតប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ព្រមទាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធាន ទាំងនោះ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។



## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ត)

**១៦-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (ត):**

**៥- សមាសធាតុកម្មវិធីទី៥** មានគោលបំណងពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការ អនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការអនុវត្តកម្មវិធីជាតិត្រូវបានបែងចែកជា ៣ដំណាក់កាល ដែលមានរយៈពេល ៣ឆ្នាំ ៣ឆ្នាំ និង ៤ឆ្នាំ ។

## VI. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ត)

**១៦-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (ត):**

<u>ថវិកា</u>

-មានការគាំទ្រជាច្រើនពីដៃគូអភិវឌ្ឍដូចជា : UNDP,UNCDF, UNICEF, UNFPA, SIDA, DANIDA, EU, GIZ, KAF, ADB,WB, JICA, NGOs ....

-មានការចូលរួមបដិភាគរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគ្រប់គម្រោង និងការវិភាជន៍ទៅឱ្យមូលនិធិឃុំ សង្កាត់ មូលនិធិឃុំសង្កាត់ មូលនិធិក្រុង ស្រុក និងថវិការាជធានី ខេត្ត.. ។



## VII. សមិទ្ធផល... (ត)

### ១. សមិទ្ធផលនៃភាពចុះសម្រុងខាងនយោបាយ

ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅអាណត្តិទី១ បានស្តែងឱ្យឃើញអំពីការសម្របសម្រួលខាងនយោបាយនៅមូលដ្ឋាន ៖

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បានសាមគ្គីសហការគ្នាកាត់បន្ថយបាននូវការបែងចែកខាងនយោបាយ
- ប្រជាជនមានការគាំទ្រ និងជឿជាក់លើរាជរដ្ឋាភិបាលកាន់តែច្រើនឡើង ។

## VII. សមិទ្ធផល... (ត)

២. សមិទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍមូលដ្ឋាន រាជរដ្ឋាភិបាលបាន ៖

- យកចិត្តទុកដាក់ទៅលើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន
- យកចិត្តទុកដាក់លើការផ្តល់ និងការបង្កើនគុណភាពសេវាសាធារណៈ ជាមូលដ្ឋាន
- រៀបចំឱ្យមានការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។



## VII. សមិទ្ធផល... (ត)

### ៣. សមិទ្ធផលនៃការផ្ទេរហិរញ្ញវត្ថុទៅថ្នាក់ក្រោមជាតិ

អំពីការវិភាជន៍ធនធានថវិការដ្ឋទៅឱ្យមូលនិធិឃុំ សង្កាត់ ដែលមានសមាមាត្រ ដូចខាងក្រោម ៖

- ឆ្នាំ២០០២=១,៥ភាគរយ, ២០០៣=២ភាគរយ, ២០០៤=២,៥ភាគរយ, ២០០៥=២,៥២ភាគរយ, ២០០៦=២,៥៤ភាគរយ, ២០០៧=២,៥៦ភាគរយ នៃប្រាក់ចំណូលចរន្តរបស់ជាតិ និង ២០០៨=២,៧០ភាគរយនៃថវិកាឆ្នាំ២០០៧ ។
- ចាប់ពីឆ្នាំ២០០២ មក កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានការ គាំទ្រយ៉ាងច្រើនពីដៃគូអភិវឌ្ឍន៍នានា ។ គ្រាន់តែឆ្នាំ២០០៨ មានចំនួន ប្រមាណជិត ៦០ លានដុល្លារអាមេរិក ។

## VII. សន្និដ្ឋាន

**សន្និដ្ឋាន ៖**

១. លទ្ធផលដែលសម្រេចបាន មានការឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺ ៖

- ពង្រឹងនិងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅកម្ពុជា
- លើកកំពស់ការចូលរួម និងភាពជាម្ចាស់របស់មូលដ្ឋាន
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ព្រមទាំងឆ្លើយតបយ៉ាងពេញលេញទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។



## VII. សន្និដ្ឋាន (ត)

២- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការផ្លាស់ប្តូរ ដ៏ជ្រាលជ្រៅនៅក្នុងរដ្ឋបាលសាធារណៈនៅកម្ពុជា ដោយ ៖

- ការបោះឆ្នោតទាំងនេះបានឆ្លើយតបទៅនឹងបទប្បញ្ញត្តិនានាដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់រៀបចំអង្គការ ក្របខ័ណ្ឌគោលនយោបាយជាតិ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ។
- តាមរយៈការបោះឆ្នោតនេះបានបង្កើតឱ្យមាននូវប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅជាអង្គភាពអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ដែលទទួលបានសិទ្ធិអំណាចពីប្រជាពលរដ្ឋ មានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពជាបឋមចំពោះមូលដ្ឋាន ។

## VII. សន្និដ្ឋាន (ត)

៣ - ការបង្កើតឡើងនូវក្រុមប្រឹក្សាទាំងនេះ បាននាំយកដំណើរការប្រជាធិបតេយ្យ និងការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមពីប្រជាពលរដ្ឋដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងនៅក្នុងកិច្ចការរបស់ក្រុមប្រឹក្សា និងលើកឡើងនូវតម្រូវការរបស់ខ្លួនដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍមូលដ្ឋាន។

៤- ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិតជាបានជំរុញឱ្យមានការបង្កើតស្ថាប័នប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ធានាដល់ការរួមចំណែកការអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ការចូលរួមការពារធនធានធម្មជាតិនិងបរិស្ថាន ការបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន សំដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។



## VIII. បញ្ហាប្រឈម និងដំណោះស្រាយ

### បញ្ហាប្រឈម

### ១. ការផ្តល់ស្វ័យភាព និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការយឺតយ៉ាវនៃការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការយឺតយ៉ាវនៃការដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធផ្ទេរមូលនិធិ និងគ្រប់គ្រងធនធានហិរញ្ញវត្ថុក្រុង ស្រុក
- ប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់សមស្របទៅនឹងចរិកលក្ខណៈផ្សេងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលតម្រូវឲ្យមានការកែលំអ

### ២. ការអភិវឌ្ឍប្រព័ន្ធប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់រឹងមាំ ដែលទាមទារឲ្យមានការពង្រឹងបន្ថែម
- ប្រព័ន្ធគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត

## VIII. បញ្ហាប្រឈម និងដំណោះស្រាយ

**បញ្ហាប្រឈម**

### ៣. ការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានភាពស៊ីសង្វាក់គ្នាជាប្រព័ន្ធនៅឡើយ

### ៤. ការងារពហុវិស័យ

- ការផ្សព្វផ្សាយព័ត៌មានពុំទាន់បានទូលំទូលាយ
- ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីពុំទាន់ត្រូវបានរៀបចំពេញលេញ និងការអនុវត្តប្រព័ន្ធនេះពុំទាន់មានភាពរលូន

89

## VIII. បញ្ហាប្រឈម និងដំណោះស្រាយ

**បញ្ហាប្រឈម**

### ៥. ការសម្របសម្រួល និងគ្រប់គ្រងកម្មវិធី

- ការសហការជាមួយស្ថាប័នអនុវត្តន៍ពុំទាន់មានភាពរលូន
- ការយល់ឃើញទៅលើកំណែទម្រង់គោលនយោបាយរបស់ស្ថាប័នអនុវត្តពុំទាន់ស៊ីសង្វាក់ទាំងស្រុងនៅឡើយ

### ៦. ការពង្រឹងភាពជាម្ចាស់របស់មូលដ្ឋាន

- ភាពជាម្ចាស់របស់មូលដ្ឋានមិនទាន់ត្រូវបានពង្រឹង

## VIII. បញ្ហាប្រឈម និង ដំណោះស្រាយ(ត)

**ខ. ដំណោះស្រាយ**

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីនៅតាមស្ថាប័នអនុវត្តអនុកម្មវិធីទាំង៦នៃផអ៣ ឱ្យមានសមត្ថភាពក្នុងការអភិវឌ្ឍគោលនយោបាយ បទដ្ឋានគតិយុត្ត នីតិវិធី ព្រមទាំងការកសាងប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាព ប្រព័ន្ធតាមដាន វាយតម្លៃ និងការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំបញ្ចប់នូវក្របខ័ណ្ឌគតិយុត្តស្តីពីយុទ្ធសាស្ត្រនៃការពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានដើម្បីធានាដល់ការចាប់ផ្តើមដំណើរការពិនិត្យមើលមុខងារ និងធនធាន ព្រមទាំងការផ្ទេរមុខងារ និងធនធានដែលសមស្រប ជាជំហានៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការអនុវត្តយុទ្ធសាស្ត្របន្សាំការប្រែប្រួលអាកាសធាតុ ពង្រឹងខ្សែគណនេយ្យភាព បញ្ជ្រាបយេនឌ័រ... នៃផអ៣។



# សូមអរគុណ !